ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
លេខៈ..០៣...ស.ណ.ន....

# សេចក្ដីណែនាំ
## ស្ដីពី
## វិធានការទប់ស្កាត់ការផ្សព្វផ្សាយ ឬ ការចែកចាយខ្លឹមសារព័ត៌មាន សារជាអក្សរ សំឡេង រូបភាព វីដេអូ និង ទម្រង់ផ្សេងៗ ដែលបណ្ដាលឱ្យមានផលប៉ះពាល់ចំពោះវប្បធម៌ទំនៀមទម្លាប់ប្រពៃណីជាតិ

ក្នុងបរិការណ៍ដែលប្រជាជាតិកម្ពុជាបាន និងកំពុងយកចិត្តទុកដាក់ចូលរួម ថែរក្សា ការពារ និងលើកកម្ពស់សុខដុមភាពនៃវិស័យសិល្បៈ វប្បធម៌ ស្របទៅតាមគោលនយោបាយជាតិ ស្ដីពីវិស័យវប្បធម៌ យ៉ាងសស្រាក់សស្រាំ និងប្រកបដោយសក្ដានុភាព ក្រុមប្រឹក្សាពិន័យនិងលើកសរសើរ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ តែងសង្កេតឃើញមានអ្នកប្រើប្រាស់ គេហទំព័រ និងបណ្ដាញទំនាក់ទំនងសង្គមមួយចំនួន ពិសេសអាជីវករតាមប្រព័ន្ធអនឡាញ (Online), អ្នកនិពន្ធបទភ្លេង ទំនុកច្រៀង និងអ្នកសម្ដែងក្រៅប្រព័ន្ធបានផ្សព្វផ្សាយរូបភាព សារជាអក្សរ/សំឡេង និងវីដេអូប្រកបដោយអសីលញាណ ប្រាសចាកក្រមសីលធម៌បង្កឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី អត្តសញ្ញាណ និងកិត្យានុភាពជាតិជារឿយៗ។

អាស្រ័យហេតុនេះ ដើម្បីបញ្ចៀសបាននូវផលប៉ះពាល់ និងដើម្បីរក្សាបាននូវសេចក្ដីថ្លៃថ្នូរព្រមទាំងគុណតម្លៃក្នុងនាមជាពលរដ្ឋកម្ពុជា **«ព្រះរាជាណាចក្រនៃវប្បធម៌»** ក្រុមប្រឹក្សាពិន័យនិងលើកសរសើរ នៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈ សូមធ្វើការណែនាំដល់អ្នកប្រើប្រាស់គេហទំព័រនិងបណ្ដាញទំនាក់ទំនងសង្គមទាំងអស់ សូមបញ្ឈប់នូវការផ្សព្វផ្សាយ គ្រប់រូបភាព សារជាអក្សរ/សំឡេង និងវីដេអូ ដែលមានចរិតលក្ខណៈអាសអាភាស ស្រើបស្រាល អុជអាល បំបែកបំបាក់ ប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ដែលបង្កឱ្យមានផលប៉ះពាល់ដល់វប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ជំនឿ សាសនា សេចក្ដីថ្លៃថ្នូរ និងកិត្យានុភាពរបស់សង្គមជាតិ ចាប់ពីថ្ងៃចេញសេចក្ដីណែនាំនេះតទៅជាកំហិត។

ក្នុងករណីដែលបុគ្គល ឬ ក្រុមណាមួយ នៅបន្តប្រព្រឹត្តសកម្មភាពអវិជ្ជមានខាងលើ ក្រុមប្រឹក្សាពិន័យនិងលើកសរសើរ នឹងសហការជាមួយក្រសួងមហាផ្ទៃ ឬ/និង ក្រសួងព័ត៌មាន ឬ/និង ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ឬ/និង ស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត ចាត់វិធានការដោយអនុលោមតាម ក្រមសីលធម៌នៃអ្នកសិល្បៈ ឬ/និង ប្រកាសអន្តរក្រសួងលេខ១៧០ប្រក.អន្តរក្រ.ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ ស្ដីពីការគ្រប់



ទូរសព្ទ / ទូរសារ: 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

គ្រងការផ្សព្វផ្សាយតាមគេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណេតនៅព្រះរាជាណាចក្រកម្ពុជា ឬ/និង ដាក់បណ្តឹងទៅតុលាការដោយអនុលោមទៅតាមក្រមព្រហ្មទណ្ឌ ឬ/និង ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ អាស្រ័យទៅតាមស្ថានបទល្មើសដែលអ្នកប្រើប្រាស់គេហទំព័រ និងបណ្តាញទំនាក់ទំនងសង្គមបានប្រព្រឹត្ត។

ក្រុមប្រឹក្សាពិន័យនិងលើកសរសើរនៃក្រសួងវប្បធម៌និងវិចិត្រសិល្បៈសង្ឃឹមនិងជឿជាក់ថា អ្នកប្រើប្រាស់គេហទំព័រនិងបណ្តាញទំនាក់ទំនងសង្គមទាំងអស់ ពិតជានឹងចូលរួមអនុវត្តស្របតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ប្រកបដោយប្រសិទ្ធិភាពខ្ពស់ជាក់ជាពុំខាន។

ថ្ងៃ សុក្រ ២រោច ខែពិសាខ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែឧសភា ឆ្នាំ២០២០

**រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**និងជាប្រធានក្រុមប្រឹក្សាពិន័យនិងលើកសរសើរ**

ភឿង-សកុណា

**កន្លែងទទួល៖**

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី

- ទីស្តីការគណៈរដ្ឋមន្ត្រី

  «ដើម្បីជូនជ្រាប»។

- ក្រសួងមហាផ្ទៃ
- ក្រសួងព័ត៌មាន
- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍
- ក្រសួងកិច្ចការនារី
- គ្រប់អង្គភាពចំណុះក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- គ្រប់មន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត

  «ដើម្បីសហការអនុវត្ត»។

- ក្រុមប្រឹក្សាពិន័យនិងលើកសរសើរ

  «ដើម្បីអនុវត្ត»។

- ឯកសារ កាលប្បវត្តិ